កិច្ចការ២៤:១-២៣

# ជំពូក ២៤

*ខាងចនា សាវ័កប៉ុលបំភ្លឺព្រះបន្ទូលនៅមុខលោកភេលីច*
*លោកភីលីចធ្វើសវនាការផ្ទាល់ជាមួយសាវ័កប៉ុល*

ជំពូក២៤ ពណ៌នាអំពីដំណើរដែលសាវ័កប៉ុលជាប់ចោទ រួចហើយគេនាំលោកយកទៅឃុំទុកនៅទីក្រុងសេសារាចាប់ពីដើមដល់ចប់។ លោកមេទ័ពបានបញ្ជូនសាវ័កប៉ុលទៅទីក្រុងសេសារាដោយចង់រំដោះលោក មិនអោយគេសម្លាប់ដោយពួកសាសន៍យូដាធ្វើឧបាយកលសម្លាត់។

បើតាមយើងវិនិច្ឆ័យទឹកចិត្តរបស់សាវ័កប៉ុល លោកយល់ថា ឥឡូវនេះលោកពិបាកបបួលជាតិសាសន៍របស់លោក អោយជឿដល់ព្រះអម្ចាស់យេស៊ូវមិនដូចមុនទៀតទេ។ បើតាមខ្ញុំយល់ នៅពេលនេះ សាវ័កប៉ុលកំពុងមានការពិបាកចិត្ត ព្រមទាំងអាចអស់ទឹកចិត្តយ៉ាងខ្លាំងផងក៏មិនដឹង។ ខ្ញុំហ៊ានសន្និដ្ឋានបែបនេះ ពីព្រោះនៅពេលដែលលោកកំពុងធ្លាក់ទឹកចិត្តយ៉ាងដុនដាបនេះហើយ ព្រះជាម្ចាស់យាងមកជួបជាមួយនឹងលោកផ្ទាល់ ដើម្បីលើកទឹកចិត្តអោយលោកខំបម្រើព្រះអង្គតទៅមុខទៀត (សូមអានគម្ពីរកិច្ចការ២៣:១១)។ ព្រះអម្ចាស់បើកសម្តែងអោយសាវ័កប៉ុលដែលត្រូវជាបាវបម្រើរបស់ទ្រង់ថា លោកចាំបាច់ត្រូវតែធ្វើទីបន្ទាល់ពីនាមព្រះអង្គ នៅក្នុងទីក្រុងរ៉ូមនៅ

ពេលខាងមុខ។ ប៉ុន្តែព្រះអង្គរំឭកសាវ័កប៉ុលជាមុនថា ដំណើរទៅធ្វើទីបន្ទាល់ពីព្រះអង្គនៅទីក្រុងរ៉ូម មិនមែនងាយស្រួលដូចលោកគិតទេ។ ដើម្បីសម្រេចកិច្ចការនោះ លោកចាំបាច់ត្រូវទៅទទួលបទពិសោធន៍យ៉ាងឈឺចាប់ ព្រមទាំងសេចក្តីទុក្ខលំបាកផ្សេងៗ។ ឯទីបញ្ចប់នៃសេចក្តីទុក្ខលំបាកនោះ គឺសាវ័កប៉ុលត្រូវគេយកទៅប្រហារជីវិតដោយកាត់កថែមទៀតផង។ ភាពតានតឹងនៅក្នុងជីវិតដែលលោកបម្រើដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ចាប់ផ្តើមរៀងរហូតមកតាំងពីគេដាក់កញ្ជើរសម្រូតលោកទម្លាក់តាមជញ្ជាំងនៅទីក្រុងដាម៉ាស។

ម្យ៉ាងនៅក្នុងជំពូក២៤ យើងឃើញថា សម្តេចសង្ឃនាមអាន៉្នានាស និងពួកសាសន៍យូដានាំគ្នាចេញដំណើរពីទីក្រុងយេរូសាឡិម ទៅធ្វើការចោទប្រកាន់ដល់សាវ័កប៉ុល តាមច្បាប់តុលាការនៅមុខលោកអភិបាលខេត្ត គឺលោកភេលីច។ គេចោទប្រកាន់សាវ័កប៉ុលថា ជាអ្នកញុះញង់បណ្តាលអោយមានអស្ថេរភាពនៅក្នុងសង្គម ជាមេនាំគេបះបោរ និងជាអ្នកដែលបង្អាប់ដល់ព្រះវិហារ។

## សាវ័កប៉ុលបំភ្លឺព្រះបន្ទូលនៅមុខលោកភេលីច

**ក្រោយ៥ថ្ងៃមក អាន៉្នានាស ជាសំដេចសង្ឃក៏ចុះទៅ ជាមួយនឹង ពួកចាស់ទុំ នាំទាំងមនុស្សម្នាក់មានវោហារ ឈ្មោះទើទូលុសទៅ**

**៨ង ដើម្បីឱ្យចូលទៅប្តឹងលោកចៅហ្វាយពីរឿងប៉ុល (កិច្ចការ ២៤:១)។**

ពួកអ្នកដើមចោទ មិនបង្អង់អោយខាតពេលវេលាទេ។ ប្រាំថ្ងៃបន្ទាប់ពីសាវ័កប៉ុលមកដល់ក្រុងសេសារា គេក៏នាំគ្នាមកចោទប្រកាន់ដល់សាវ័កប៉ុលតាមច្បាប់តុលាការរបស់រាជការរ៉ូម។ នៅពេលដែលក្រុមគណៈសង្ឃទាំងនោះមកចោទប្រកាន់ គេនាំទាំងលោកទើទូលុស ដែលត្រូវជាមេធាវីរបស់អ្នកដើមចោទមកជាមួយផង។ មេធាវីរូបនេះ ជាមនុស្សឆ្លាតវាងវៃ ពូកែលេងល្បិចនៅជុំវិញគុម្ពោតច្បាប់ណាស់។ ការចោទប្រកាន់ទៀតសោតក៏បានរៀបរយ ព្រមទាំងមានសាក្សីយ៉ាងគ្រប់គ្រាន់។ មេធាវីដើមចោទរូបនេះ ត្រៀមលក្ខណៈគ្រប់បែបយ៉ាងដែលលោកអាចធ្វើទៅបាន ដើម្បីចោទប្រកាន់ដល់សាវ័កប៉ុល។

**កាលលោកបានហៅប៉ុលមក នោះទើទូលុសចាប់ចោទប្រកាន់គាត់ថា (កិច្ចការ២៤:២)។**

មេធាវីរបស់ពួកគណៈសង្ឃ ចាប់ផ្តើមដោយនិយាយពាក្យបញ្ជើចដល់លោកចៅហ្វាយខេត្តភេលីច។ មកទល់ពេលនេះ គេមិនទាន់យកកំហុសរបស់សាវ័កប៉ុល មកចោទលោកនៅឡើយ។

**ឱព្រះតេជ ព្រះគុណភេលីចអើយ សាសន៍យើងខ្ញុំបានសេចក្ដីសុខប្រពៃ ដោយសារលោកម្ចាស់ ក៏មានចំរើនការផ្លាស់ប្រែយ៉ាងប្រសើរ ដែលមានប្រយោជន៍ដល់សាសន៍យើងខ្ញុំនេះដោយសារគំនិតលោកម្ចាស់ ហើយទោះបើនៅវេលាណា ឬកន្លែងណាក៏ដោយ គង់តែយើងខ្ញុំទទួលការទាំងនោះដោយអំណរ ទាំងអរគុណដល់លោកម្ចាស់គ្រប់ជំពូកដែរ (កិច្ចការ២៤:៣)។**

ខ្ញុំជឿថា លោកចៅហ្វាយខេត្តភេលីចច្បាស់ជាឡើងឈាមខ្លាំងណាស់ នៅក្នុងពេលនេះ។ ប៉ុន្តែសុំកុំភ្លេចថា លោកភេលីចជាអ្នកនយោបាយយ៉ាងប៉ិនប្រសប់មួយរូបដែរ។

**៤ តែដើម្បីកុំឱ្យបង្ខាតពេលលោកម្ចាស់ទៀត នោះសូមមេត្តាស្តាប់យើងខ្ញុំបន្តិច ៥ ដ្បិតយើងខ្ញុំបានឃើញថា អ្នកនេះជាមនុស្សចង្រៃជាមេនៃពួកណាសារ៉ែត ដែលញុះញង់ឱ្យពួកសាសន៍យូដាទាំងអស់ នៅលោកីយនេះបះបោរឡើង (កិច្ចការ២៤:៤-៥)។**

ឥឡូវ មេធាវីចាប់ផ្ដើមចោទប្រកាន់សាវ័កប៉ុលតាមផ្លូវច្បាប់ហើយ។ ដំបូងបង្អស់ គេចោទប្រកាន់សាវ័កប៉ុលថា ជាមនុស្សញុះញង់ដល់សាសន៍យូដា។ ប៉ុន្តែ ពាក្យ

ចោទកាន់នេះមិនមានភ័ស្តុតាងអ្វីគ្រប់គ្រាន់ទេ។

> **[៦]ក៏ចង់ធ្វើបង្អាប់ដល់ព្រះវិហារផង នោះយើងខ្ញុំបានចាប់វាមក**
> **ប្រាថ្នាចង់ជំនុំជំរះតាមក្រិត្យវិន័យរបស់យើងខ្ញុំ [៧]ប៉ុន្តែ លោក**
> **លូស៊ា ជាមេទ័ពធំ បានមកកន្ត្រាក់យកវាពីដៃយើងខ្ញុំទៅ ដោយ**
> **អំណាចយ៉ាងសំបើម [៨]ទាំងបង្គាប់ឱ្យពួកដើមចោទមកឯលោក**
> **ម្ចាស់ បើកាលណាលោកម្ចាស់បានពិចារណាវា នោះនឹងបាន**
> **ជ្រាបពីគ្រប់ទាំងការ ដែលយើងខ្ញុំចោទប្រកាន់ដល់វាហើយ [៩]ឯ**
> **ពួកសាសន៍យូដា ក៏យល់ព្រមដែរ ដោយបញ្ជាក់ថា រឿងទាំង**
> **នោះប្រាកដមែន (កិច្ចការ២៤:៦-៩)។**

ពាក្យថា សាសន៍យូដាដែលមេធាវីនិយាយនេះ គឺជាពួកអ្នកដឹកនាំសាសនាយូដា នៅក្នុងពួកគណៈសង្ឃដែលធ្វើដំណើរមកជាមួយលោកនេះហើយ។ អ្នកទាំងនោះមកជាមួយមេធាវីដើម្បីចោទប្រកាន់ដល់សាវ័កប៉ុល។

បើលោកអ្នកសង្កេតអោយបានច្បាស់លាស់អំពីពាក្យសម្តីរបស់មេធាវី លោកទើទីលូសហ៊ានទាំងនិយាយអាក្រក់ពីលោកមេទ័ព ដែលបានរំដោះសាវ័កប៉ុលយកមកឃុំទុកក្នុងក្រុងសេសារា។ គាត់មិនបានចោទប្រកាន់ថា លោកមេទ័ពមិនបានបំពេញភារកិច្ចរបស់លោកទេ គឺលោកគ្រាន់តែសម្តែងការរិះគន់ដល់កិរិយាប្រព្រឹត្តរបស់លោក

មេទ័ពតែប៉ុណ្ណោះ។ លោកចោទប្រកាន់មេទ័ពថា រឿងសាសនាយូដា ជារឿងផ្ទៃក្នុងរបស់សាសន៍យូដាទេ លោកមេទ័ពមិនគួរលូកដៃលូកជើងចូលក្នុងរឿងនោះឡើយ។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ មេធាវីរូបនេះ មិនទាន់អាចចោទប្រកាន់សាវ័កប៉ុលបានក្រៅអំពីនិយាយបញ្ជោរដល់ចៅហ្វាយខេត្តទេ។

បន្ទាប់ពីនិយាយបញ្ជោរចៅហ្វាយខេត្តរួចហើយ មេធាវីរូបនោះក៏ចោទប្រកាន់ដល់សាវ័កប៉ុលថា លោកជាមេដែលញុះញង់ដល់បណ្តាជន លោកជាមេនៃអ្នកនាំគេបះបោរ ព្រមទាំងជាអ្នកបង្អាប់ដល់ព្រះវិហារផង។ លោកទើទូលុស គឺជាមេធាវីដែលកាន់ក្តីអោយគណៈសង្ឃ។ ឥឡូវនេះ ចៅហ្វាយខេត្តភេលីចបានអនុញ្ញាតអោយសាវ័កប៉ុលបំភ្លឺរឿងក្តីដែលគេចោទប្រកាន់ដល់លោក។

> **១០"កាលលោកចៅហ្វាយ បានធ្វើគ្រឿងសំគាល់ ឱ្យប៉ុលនិយាយ នោះគាត់ឆ្លើយឡើងថា ខ្ញុំប្របាទនឹងដោះសារឿងខ្លួនដោយអំណរ ដោយដឹងថា ព្រះតេជព្រះគុណបានធ្វើជាចៅក្រមលើសាសន៍នេះជាយូរឆ្នាំហើយ ១១ក៏អាចនឹងជ្រាបថា តាំងពីខ្ញុំប្របាទឡើងទៅថ្វាយបង្គំឯក្រុងយេរូសាឡិម នោះមិនលើសពី១២ថ្ងៃទេ (កិច្ចការ២៤:១០-១១)។**

សាវ័កប៉ុលចាប់ផ្ដើមនិយាយដោយសម្ដែងការអរគុណ ដល់ចៅហ្វាយខេត្ត ភេលីច ដែលអនុញ្ញាតអោយលោកមានឱកាសពន្យល់សាច់រឿងដែលបានកើតឡើងកន្លងមក។ សាវ័កប៉ុលជ្រាបច្បាស់ថា លោកភេលីចមិនមែនគ្រាន់តែជាចៅហ្វាយខេត្តប៉ុណ្ណោះទេ លោកជាចៅក្រមដើងចាស់ថែមទៀត។ លោកកាន់តំណែងនៅស្រុកយូដានេះយូរហើយ បានជាលោកស្គាល់អស់ទាំងទំនៀមទម្លាប់ប្រពៃណីនិងផ្នត់គំនិតសាសនារបស់អ្នកស្រុកនេះ។ ដូច្នេះ សាវ័កប៉ុលមិននិយាយសេចក្ដីអ្វីដែលលោកភេលីចមិនបានជ្រាបជាមុននោះទេ។

> **[១២]គេក៏មិនបានឃើញខ្ញុំប្របាទ កំពុងដែលជជែកនឹងអ្នកណា នៅក្នុងព្រះវិហារ ឬប្រមូលញុះញង់បណ្ដាមនុស្សដែរ ទោះបើក្នុងសាលាប្រជុំគេ ឬកន្លែងណានៅក្នុងទីក្រុងក្ដី [១៣]គេពុំអាចនឹងរកភស្តុតាង ពីការដែលគេចោទខ្ញុំប្របាទឥឡូវនេះបានទេ [១៤]ប៉ុន្តែសូមជំរាបលោកម្ចាស់តាមត្រង់ថា ខ្ញុំប្របាទគោរពប្រតិបត្តិដល់ព្រះនៃពួកឰយុកោយើងខ្ញុំ តាមរបៀបដែលគេហៅថា ក្បត់សាសនា ដោយមានសេចក្ដីជំនឿជឿដល់អស់ទាំងសេចក្ដី ដែលចែងទុកមកក្នុងក្រិត្យវិន័យ នឹងក្នុងគម្ពីរពួកហោរា (កិច្ចការ២៤:១២-១៤)។**

ចៅហ្វាយខេត្តភេលិច យល់ដឹងយ៉ាងច្បាស់អំពីទំនៀមទម្លាប់របស់សាសន៍យូដា។ ដូច្នេះហើយ បានជាសាវ័កប៉ុលជម្រាបថា តាមទំនៀមទម្លាប់របស់លោក លោកតែងតែទៅទីក្រុងយេរូសាឡិម ដើម្បីថ្វាយបង្គំដល់ព្រះជាម្ចាស់។ លោកជម្រាបដល់ចៅហ្វាយខេត្តភេលិចថា "...ខ្ញុំប្របាទគោរពប្រតិបត្តិដល់ព្រះនៃពួកឰយុកោយើងខ្ញុំតាមរបៀបដែលគេហៅថា ក្បត់សាសនា..."។ សាវ័កប៉ុលបញ្ជាក់ថា លោកថ្វាយបង្គំដល់ព្រះជាម្ចាស់ គឺថ្វាយបង្គំដោយសេចក្ដីពិតនិងដោយវិញ្ញាណ ដូចព្រះអម្ចាស់យេស៊ូវមានបន្ទូលនៅក្នុងគម្ពីរយ៉ូហាន។ ពួកសាសនាយូដាកាន់សាសនារបស់ព្រះ ប៉ុន្តែកាន់តែសំបកក្រៅទេ ចិត្តខាងក្នុងមិនបាននៅខ្ជាប់ខ្ជួនជាមួយព្រះអង្គឡើយ។ ចំណែកសាវ័កប៉ុលវិញ លោកថ្វាយបង្គំទាំងកិរិយាខាងក្រៅ ទាំងកិរិយាដែលនៅក្នុងចិត្តរបស់លោក។ ដោយសារមូលហេតុនោះហើយ បានជាគេហៅលោកថា ជាអ្នកក្បត់សាសនា។ សាវ័កប៉ុលបញ្ជាក់យ៉ាងច្បាស់ថា លោកមិនមែនជាអ្នកក្បត់សាសនាទេ ពោលគឺលោកជាអ្នកប្រតិបត្តិដល់ព្រះ ដែលឪពុកម្ដាយ ជីដូនជីតាម៉ាកុងរបស់លោកបានបន្សល់ទុកនៅក្នុងព្រះគម្ពីរសញ្ញាចាស់។

**ហើយខ្ញុំប្របាទមានសេចក្ដីសង្ឃឹមដល់ព្រះ ដែលគេក៏យល់ព្រមដែរ គឺថា ទាំងមនុស្សសុចរិត នឹងមនុស្សទុច្ចរិត នឹងបានរស់ឡើងវិញទាំងអស់គ្នា (កិច្ចការ២៤:១៥)។**

សាវ័កប៉ុលបញ្ជាក់យ៉ាងច្បាស់ម្តងទៀត អំពីបញ្ហាការរស់ឡើងវិញ នៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលត្រូវជាបេះដូងនៃជំនឿរបស់ពួកគ្រីស្ទបរិស័ទ។ កត្តាដែលព្រះអម្ចាស់យេស៊ូវរស់ពីសុគតឡើងវិញ គឺជាកត្តាសំខាន់បំផុត ដែលមិនអាចអត់បាននៅក្នុងជំនឿរបស់អ្នកដើរតាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ព្រះអម្ចាស់យេស៊ូវត្រូវគេធ្វើគុតហើយយកទ្រង់ទៅបញ្ចុះនៅក្នុងផ្នូរ បីថ្ងៃក្រោយមក ទ្រង់រស់ពីសុគតឡើងវិញ។ អស់អ្នកណាដែលជឿដល់បេះដូងនៃដំណឹងល្អនេះ អ្នកនោះព្រះអម្ចាស់រាប់ថា ជាអ្នកសុចរិត ព្រមទាំងជាកូនរបស់ព្រះអង្គផង។ ខ្ញុំចង់ដណ្តឹងសួរដល់លោកអ្នកបងប្អូននៅក្នុងថ្ងៃនេះថា តើលោកអ្នកបងប្អូនគិតថាព្រះអម្ចាស់យេស៊ូវជាអង្គណាដែរ? លោកអ្នកចាំបាច់ត្រូវឆ្លើយថា អង្គព្រះយេស៊ូវជាអង្គសង្គ្រោះរបស់លោកអ្នកបងប្អូន ឬមួយក៏លោកអ្នកបងប្អូនគ្រាន់តែគិតថា ព្រះអម្ចាស់យេស៊ូវជាអង្គណាមួយ តាមតែចិត្តរបស់លោកអ្នកបងប្អូនយល់ឃើញ។ តើលោកអ្នកជឿថា ព្រះអម្ចាស់យេស៊ូវសុគតជំនួសអំពើបាបរបស់លោកអ្នកដែរឬទេ? តើលោកអ្នកជឿថា ព្រះអង្គរស់ពីសុគតឡើងវិញដែរឬទេ? សាវ័កប៉ុលពន្យល់អំពីស្នូលនៃដំណឹងល្អ ពោលគឺជាការរស់ពីសុគតឡើងវិញនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

> **ហេតុនោះ បានជាខ្ញុំប្រឹងប្រែងឲ្យមានបញ្ញាចិត្តឥតសៅហ្មង នៅចំពោះព្រះ នឹងនៅចំពោះមនុស្សលោកជានិច្ចដែរ (កិច្ចការ ២៤:១៦)។**

សាវ័កប៉ុលបញ្ជាក់ថា អ្វីៗទាំងអស់ដែលលោកធ្វើកន្លងមក លោកគោរពតាមឆន្ទៈជ្រះថ្លារបស់លោក ស្តីអំពីការសម្រេចចិត្តលើអង្គព្រះយេស៊ូវ។ លោកមានការប្រាកដក្នុងចិត្តថា ព្រះអម្ចាស់យេស៊ូវសុគតជំនួសអំពើបាបរបស់លោក ត្រូវគេបញ្ចុះនៅក្នុងផ្នូរ តែបីថ្ងៃក្រោយមក ព្រះអង្គមានព្រះជន្មរស់ពីសុគតឡើងវិញ។ ការប្រាកដនៅក្នុងចិត្តនេះ គឺជាការជ្រើសរើសក្នុងឆន្ទៈដោយសេរីរបស់លោក។ លោកចង់បញ្ជាក់អំពីសេរីភាពដែលលោកមានជំនឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

**លុះក្រោយដែលខ្ញុំប្របាទបានចោលស្រុកទៅជាយូរឆ្នាំ នោះក៏ត្រឡប់មកធ្វើទានវិញ ព្រមទាំងយកជំនូនមក ជូនដល់សាសន៍របស់ខ្ញុំប្របាទ (កិច្ចការ២៤:១៧)។**

សាវ័កប៉ុលនាំបញ្ញើនានា ដែលក្រុមជំនុំសាសន៍ដទៃផ្ញើមកអោយពួកជំនុំនៅទីក្រុងយេរូសាឡិម។ បញ្ញើទាំងនោះ លោកទទួលបានពេលលោកធ្វើដំណើរបេសកកម្មទៅផ្សាយដំណឹងល្អលើកទីបី។ បញ្ញើនោះមានចំនួនច្រើន ព្រមទាំងមានតម្លៃថ្លៃណាស់ បានជាលោកចាំបាច់ត្រូវយកបញ្ញើទាំងនោះ ទៅប្រគល់អោយពួកជំនុំនៅទីក្រុងយេរូសាឡិមដោយផ្ទាល់ដៃលោក។ ពួកជំនុំជាសាសន៍ដទៃបានរៃប្រមូលបញ្ញើទាំងអម្បាលមាណនោះ យកមកធ្វើពួកបរិសុទ្ធនៅទីក្រុងយេរូសាឡិម។ ត្រង់នេះ ខ្ញុំចង់បញ្ជាក់ជម្រាបលោកអ្នកបងប្អូនថា ក្រុមជំនុំដែលជាសាសន៍ដទៃ ចេះគិតគូរអំពីក្រុមជំនុំ

ដែលជាក្រុមជំនុំដើម។ គេមិនគ្រាន់តែគិតគូរក្នុងចិត្តតែប៉ុណ្ណោះទេ គឺគេចេះលើកដង្វាយផ្ញើមកជូនពួកចាស់ទុំ និងឥស្សរជនជាន់ខ្ពស់នៅក្នុងទីក្រុងយេរូសាឡិមទៀតផង។ករណីនេះរាប់ថា ជាការដឹងគុណដល់អ្នកដែលនាំដំណឹងល្អទៅដល់រូបគេ។ មេរៀននេះ យើងជាក្រុមជំនុំដែលទើបនឹងកកើត គួរចេះគិតគូអំពីការថ្វាយដង្វាយដល់ពួកជំនុំដែលចេញទៅបង្កើតអោយមានក្រុមជំនុំថ្មីៗនោះផង។

> **[១៨]ហើយកំពុងដែលខ្ញុំប្របាទរវល់នឹងការនោះ គេក៏ឃើញខ្ញុំប្របាទបានញែកជាបរិសុទ្ធនៅក្នុងព្រះវិហារ មិនមែនមានមនុស្សទាំងហ្វូង ឬដោយវឹកវរទេ ប៉ុន្តែមានពួកសាសន៍យូដាខ្លះពីស្រុកអាស៊ីបានឃើញខ្ញុំប្របាទ [១៩]ដែលគួរឱ្យគេមកចោទប្រកាន់ខ្ញុំប្របាទនៅមុខលោកម្ចាស់វិញ បើសិនជាគេមានរឿងអ្វីទាស់នឹងខ្ញុំប្របាទ (កិច្ចការ២៤:១៨-១៩)។**

បើតាមប្រសាសន៍របស់សាវ័កប៉ុលនៅក្នុងខនេះ អ្នកដែលមានគំនិតចោទប្រកាន់ដល់សាវ័កប៉ុលនោះ មិនបានចេញមុខមកក្នុងពេលនេះទេ។ លោកទើទូលុសគឺជាមេធាវីដែលនាំពាក្យចោទប្រកាន់ទាំងអម្បាលមាណពីមនុស្សមួយពួក យកមកចោទប្រកាន់សាវ័កនៅមុខចៅហ្វាយខេត្តភេលីច។ ពាក្យដែលគេចោទប្រកាន់នោះ គឺថាលោកជាអ្នកញុះញង់ដល់បណ្តាជននៅក្នុងព្រះវិហារទីក្រុងយេរូសាឡិម។ បើសាវ័កប៉ុល

ពិតជាធ្វើការញុះញង់យ៉ាងដូច្នោះមែន ហេតុអ្វីបានជាអ្នកចោទប្រកាន់ទាំងនោះមិនហ៊ានចេញមុខមកឈរនៅចំពោះមុខច្បាប់? ដូច្នេះ ហើយបានជាសាវ័កប៉ុលបញ្ជាក់ថា អ្នកចោទប្រកាន់ដល់លោក មិនបានហ៊ានចេញមុខមកជួបលោកនៅមុខច្បាប់តុលាការឡើយ។

> **ឬឱ្យអ្នកទាំងនេះធ្វើបន្ទាល់ចុះ បើគេឃើញខ្ញុំប្របាទមានសេចក្តីទុច្ចរិតណា ក្នុងកាលដែលឈរនៅមុខក្រុមជំនុំនោះ (កិច្ចការ ២៤:២០)។**

ខខាងលើគ្រាន់តែជាការបញ្ជាក់ម្តងទៀតថា បើគណៈសង្ឃទាំងនោះ ឃើញថា សាវ័កប៉ុលពិតជាធ្វើខុសមែន ហេតុអ្វីបានជាលោកទាំងនោះមិនហ៊ានចេញមុខមកជួបជាមួយនឹងសាវ័កប៉ុល?

> **លើកតែពាក្យ១ម៉ាត់នេះចេញ ដែលខ្ញុំប្របាទស្រែកឡើងនៅពេលកំពុងឈរជាកណ្តាលពួកគេថា ថ្ងៃនេះ ខ្ញុំត្រូវអ្នករាល់គ្នាជំនុំជំរះពីដំណើររស់ពីស្លាប់ឡើងវិញប៉ុណ្ណោះ (កិច្ចការ២៤:២១)។**

សាវ័កប៉ុលជម្រាបម្តងទៀត អំពីបញ្ហាទាក់ទងនឹងការរស់ពីសុគតឡើងវិញនៃ

ព្រះអម្ចាស់យេស៊ូវ អោយលោកចៅហ្វាយខេត្តភេលីចបានជ្រាបផង។ ការរស់ពីសុគត ឡើងវិញរបស់ព្រះអម្ចាស់យេស៊ូវ គឺជាបេះដូងនៃដំណឹងល្អ។ ឯស្នូលនៃដំណឹងល្អនោះ គឺព្រះយេស៊ូវសុគត ត្រូវគេបញ្ចុះ រួចហើយបីថ្ងៃក្រោយមកព្រះអង្គទ្រង់រស់ពីសុគតឡើង វិញ។ ជំនឿរបស់គ្រីស្ទបរិស័ទមានសសររឹងមាំចំនួនពីរដើមដែលទ្រទ្រង់។ សសរទាំង ពីរនេះ មិនអាចមានមួយ អត់មួយបានឡើយ។ សសរទីមួយ គឺព្រះយេស៊ូវសុគតជំនួស មនុស្សមានបាប។ ឯសសរទីពីរ គឺព្រះអម្ចាស់យេស៊ូវរស់ពីសុគតឡើងវិញ។ បើគ្មាន សសរណាមួយនៅក្នុងចំណោមសសរទាំងពីរនោះទេ វិមានជំនឿរបស់គ្រីស្ទបរិស័ទ ត្រូវរលំស្រុតសាបរលាបអស់ជាពិតប្រាកដ។

> **ឯលោកភេលីច ដែលដឹងជ្រៅជ្រះខាងសាសនានេះដែរ កាលបាន ស្តាប់សេចក្តីចោទឆ្លើយរួចហើយ នោះលោកក៏ផ្អាករឿងនោះសិន ដោយថា កាលណាលោកលូស៊ា ជាមេទ័ពធំបានចុះមក នោះចាំ ខ្ញុំនឹងពិចារណារឿងអ្នករាល់គ្នាទៀត (កិច្ចការ២៤:២២)។**

ចៅហ្វាយខេត្តភេលីចធ្លាប់បានឮអំពីពាក្យដែលគេនិយាយថា "ផ្លូវនេះ"។ លោកជ្រាបច្បាស់អំពីដំណើររឿងដែលព្រះយេស៊ូវបានសុគត ព្រមទាំងរស់ឡើងវិញ ដ្បិតលោកតែងតែឮពួកគ្រីស្ទបរិស័ទអធិប្បាយពន្យល់អំពីដំណើរនោះ។ លោកចៅហ្វាយ ខេត្តរូបនេះ ក៏យល់ថា សាវ័កប៉ុល គឺជាអ្នកជំនាញខាងសេចក្តីអធិប្បាយដែលប្រកាន់ថា

ព្រះយេស៊ូវសុគតជំនួសមនុស្សមានបាប ព្រមទាំងរស់ឡើងវិញ បន្ទាប់ពីគេបញ្ចុះទ្រង់នៅក្នុងផ្នូរបីថ្ងៃក្រោយមក។ សាវ័កប៉ុលអាចពន្យល់ដល់មនុស្សគ្រប់រូបអំពីដំណើរការរស់ឡើងវិញនៃព្រះអម្ចាស់យេស៊ូវ តាំងពីដើមដល់ចប់។ ប៉ុន្តែ ទោះបីលោកចៅហ្វាយខេត្តជ្រាបអំពីដំណើរនោះច្បាប់យ៉ាងណាក៏ដោយ លោកមិនទោរទន់ទៅតាមការចោទប្រកាន់របស់សាសន៍យូដាទេ។ ក្នុងនាមលោកជាចៅក្រមជើងចាស់មួយរូប លោកចាំបាច់ត្រូវការភ័ស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្រការចោទប្រកាន់របស់សាសន៍យូដា ចំពោះសាវ័កប៉ុល។ លោកចាំបាច់ត្រូវហៅមេទ័ពមកពន្យល់លោកសិន។ ដូច្នេះហើយ បានជាលោកមានប្រសាសន៍ទៅកាន់សាសន៍យូដា ដែលនាំពាក្យចោទប្រកាន់មកដល់សាវ័កប៉ុលថា នៅពេលដែលលោកលូស៊ាមកដល់ ខ្ញុំនឹងហៅអ្នកទាំងអស់គ្នាមកចូលសាលាក្តីម្តងទៀត ដើម្បីស្តាប់រឿងនេះ។ លោកមេទ័ពមិនអាចសម្រេចធ្វើអ្វីបាននៅក្នុងពេលនេះទេ ពីព្រោះអ្នកដើមចោទនិយាយរឿងផ្សេង ឯអ្នកចុងចោទនិយាយរឿងផ្សេងមួយទៀត។ មេធាវីរបស់អ្នកដើមចោទ គឺលោកទើទូលុសចោទប្រកាន់ថា សាវ័កប៉ុលបានញុះញង់ដល់ពួកបណ្តាជន នាំគេបង្កើតចលនាបះបោរ ព្រមទាំងបង្អាប់ព្រះវិហារ។ ចំណែកសាវ័កប៉ុលវិញ លោកមិនបាននិយាយអំពីដំណើរនោះទេ គឺថា គេចោទប្រកាន់លោកដោយព្រោះតែលោកជឿថា ព្រះអម្ចាស់យេស៊ូវរស់ពីសុគតឡើងវិញប៉ុណ្ណោះ។ ដូច្នេះ ហើយបានជាលោកពន្យាការសម្រេចចិត្តតាមផ្លូវច្បាប់តុលាការមិនសម្រេចក្តីអោយសាសន៍យូដា ដែលនាំពាក្យចោទប្រកាន់មកដល់សាវ័កប៉ុល នៅក្នុងពេលនេះឡើយ។

**រួចលោកបង្គាប់មេទ័ពរងឱ្យរក្សាប៉ុលដោយស្រួលបួល ឥតឃាត់ហាមពួកគាត់ណាមួយ មិនឱ្យមកបំរើគាត់នោះឡើយ (កិច្ចការ ២៤:២៣)។**

បើតាមច្បាប់របស់រាជការរ៉ូម លោកភេលីចអាចដោះលែងសាវ៉កប៉ុលអោយមានសេរីភាពក្នុងពេលនេះបានហើយ។ ប៉ុន្តែ សូមលោកអ្នកជ្រាបថា លោកភេលីចគឺជាអ្នកនយោបាយជើងចាស់។ ធម្មតាអ្នកនយោបាយ គេតែងតែឆក់ឱកាសជានិច្ច។ បើហេតុការណ៍នោះជារឿងតូច ប៉ុន្តែ មានប្រយោជន៍ដល់មាគ៌ានយោបាយរបស់គេ គេពង្រីករឿងនោះ អោយរីតតែធំឡើង។ ប៉ុន្តែ បើរឿងនោះជារឿងធំ ប៉ុន្តែគ្មានប្រយោជន៍ដល់មាគ៌ានយោបាយរបស់គេទេ គេពន្លិចមិនចង់អោយនរណាដឹងពីរឿងនោះឡើយ។ លោកភេលីចជាអ្នកនយោបាយ ដែលមានគំនិតមិនខុសពីអ្នកនយោបាយទូទៅនៅលើសកលលោកឡើយ។ ប៉ុន្តែ ទោះបីលោកមិនបានដោះលែងសាវ៉កប៉ុលអោយរួចនៅក្នុងពេលនេះ លោកបានផ្តល់អោយសាវ៉កប៉ុលមានសេរីភាពជាអតិបរមាគ្រាន់តែមានឈ្មោះថា ជាអ្នកជាប់ឃុំឃាំងប៉ុណ្ណោះ។ លោកអនុញ្ញាតអោយមនុស្សចូលមកបម្រើសាវ៉កប៉ុល តាមចិត្តលោកចង់។ សាវ៉កប៉ុលមានសិទ្ធិសរសេរសំបុត្រគ្រប់បែបយ៉ាង ដូចយើងបានឃើញសំបុត្ររបស់លោកនៅក្នុងព្រះគម្ពីរសញ្ញាថ្មីហើយ។ សាវ៉កប៉ុល ថ្វីដ្បិតមានឈ្មោះថាជាអ្នកជាប់គុក តែលោកមានសេរីភាព មិនខុសអំពីមនុស្សធម្មតាឡើយ។ ការនេះកើតឡើងមកពីជំហរការពាររបស់ចៅហ្វាយខេត្តភេលីច។

តើលោកអ្នកយល់ថា រឿងនេះកើតឡើងក្រៅពីបំណងព្រះហឫទ័យរបស់ព្រះដែលថែរក្សាសាវ័កប៉ុលឬ? ខ្ញុំយល់ថា ព្រះជាម្ចាស់កំពុងគ្រប់គ្រងស្ថានភាព ទោះបីយើងមើលទៅហាក់ដូចជាមានការលំបាកយ៉ាងណាក៏ដោយ។

ដំណើររឿងសាវ័កប៉ុលជាប់ឃុំឃាំងនៅទីក្រុងសេសារា បន្សល់ទុកនៅមេរៀនសម្រាប់យើងជាគ្រីស្ទបរិស័ទ ដែលដើរជាមួយនឹងព្រះអង្គរៀងរាល់ថ្ងៃ។ អ្នកដែលស្រឡាញ់ព្រះអង្គពិតប្រាកដ ពិតជាជួបជាមួយនឹងទុក្ខលំបាកខ្លះៗជាមិនខាន។ មានគ្រីស្ទបរិស័ទដែលជាពួកបរិសុទ្ធរបស់ព្រះយេស៊ូវខ្លះ រងទុក្ខរហូតដល់យើងទាំងអស់គ្នាមើលទៅមិនគួរអោយអ្នកទាំងនោះឆ្លងកាត់យ៉ាងដូច្នោះឡើយ។ ប៉ុន្តែ រឿងនេះព្រះជាម្ចាស់ជាអ្នកដែលគ្រប់គ្រងស្ថានភាពទាំងឡាយនៃជីវិតរបស់គ្រីស្ទបរិស័ទ ដែលកំពុងរងទុក្ខលំបាកនោះ។ ទោះបីស្ថានភាពដែលគ្រីស្ទបរិស័ទឆ្លងកាត់ មានលក្ខណៈលំបាក ឬស្រួលយ៉ាងណាក្តី ព្រះជាម្ចាស់នៅតែមានអាទិភាពនៅលើបញ្ហានោះជានិច្ច។ ព្រះហស្តរបស់ព្រះអង្គតែងតែគ្រប់គ្រង ដ្បិតព្រះអង្គសន្យាថា ទ្រង់មិនដែលចាកចោលយើងឡើយ។ មេរៀននេះ ទុកជាការលើកទឹកចិត្តដល់យើងទាំងអស់គ្នា ដែលជាអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវ ព្រមទាំងជាអ្នកបម្រើព្រះអង្គដោយចិត្តស្មោះត្រង់។

យើងស្លេះការសិក្សាគម្ពីរកិច្ចការតែត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"